# ៥—ទីស្តីការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

## ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ៦៤០ សករ**

**ស្តីពីការបង្កើតការិយាល័យអាស៊ាន**

**រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ**

**និង អតីតយុទ្ធជន**

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

–បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រមលេខ នស.រកម ០៩៦.១៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

–បានឃើញរបាយការណ៍លេខ ៣៥ សស ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៩៦ ស្តីពីលទ្ធ ផលនៃការចូលរួមប្រជុំអន្តរក្រសួងអំពីការងារអាស៊ាន

–ពិនិត្យឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : បង្កើតការិយាល័យអាស៊ានមួយ ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធានស្ថាប័ននៃក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ដើម្បីវិភាគ និង គ្រប់គ្រងការងារអាស៊ានប្រកបដោយនិរន្តភាព ។

**ប្រការ ២** : ការិយាល័យអាស៊ានមានភារកិច្ចដូចតទៅ :

–ជាលេខាធិការរបស់ក្រសួងក្នុងកិច្ចការសំរបសំរួលរាល់ការងារអាស៊ាន ជាមួយនឹងអគ្គនាយកដ្ឋានអាស៊ាននៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

–ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គភាពអាស៊ាននៃក្រសួងនានា

–ទំនាក់ទំនងជាមួយអង្គភាពនានា ដែលស្ថិតនៅក្រោមឱវាទក្រសួង ស្រង់បាននូវពត៌មានសំខាន់ៗ និង សំណូមពរដែលពាក់ព័ន្ធដល់ការងារអាស៊ាន ។

–ចូលរួមប្រជុំតាមកម្មវិធីកំណត់ប្រចាំឆ្នាំនៃអង្គការអាស៊ាន ដែលពាក់ព័ន្ធលើវិស័យការងារសង្គមកិច្ច និង អតីតយុទ្ធជន ។

–ផ្សព្វផ្សាយពត៌មានអំពីសកម្មភាពអាស៊ាន ជូនដល់មន្ត្រីរាជការនៅក្នុងក្រសួង ។

–លើគំរោងថវិកា ចំណាយប្រចាំឆ្នាំនីមួយៗ សំរាប់ការងារអាស៊ានរបស់ក្រសួង ។

–ធ្វើរបាយការណ៍អំពីសកម្មភាពការងារ ដែលពាក់ព័ន្ធនឹងកិច្ចការអាស៊ានទៅតាមរបបកំណត់ នៃអគ្គនាយកដ្ឋានអាស៊ានជាតិ ។

**ប្រការ ៣** : លោកប្រធានមន្ទីរលោកប្រធានអង្គភាពនានា ក្រោមឱវាទក្រសួងសង្គមកិច្ចការងារ មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**

* * *

## ៦–ឧស្សិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ១–សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ១២៩ បទ**

**ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យតាមក្រុមហ៊ុនដែលធ្វើអាជីវកម្ម សេវា ប្រៃសណីយ៍ ក្នុងរាជធានីភ្នំពេញ**

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា